# Cellcard Club

## Call Tunes, wallpapers and screen logos

| | | |
|---|---|---|
| 1 | មនុស្សជិតខ្លួន | 882572 |
| 2 | Merry X'mas | 882609 |
| 3 | Christmas បាត់ស្នេហ៍ | 882610 |
| 4 | អូននៅតែស្រលាញ់រូបបង | 882575 |
| 5 | បេះដូងអនាថា | 882576 |
| 6 | បេះដូងក្រុងក្តៅ | 882577 |
| 7 | សមុទ្រស្ងប់ខ្យល់ | 882578 |
| 8 | ក្រោមមេឃទិទៃ | 882579 |
| 9 | នាងសុនីតា | 882580 |
| 10 | ព្រះនាង | 882581 |
| 11 | ចាំថ្ងៃបងវិលវិញ | 882582 |
| 12 | សុំបានទេ | 882583 |
| 13 | ឈឺសែនឈឺ | 882584 |
| 14 | ចាំទាំងក្រៀម | 882585 |
| 15 | លំបាក | 882586 |
| 16 | ចម្រៀងបេះដូង | 882587 |
| 17 | បងខឹង | 882588 |
| 18 | មិនសន្យាតែចាំសម័យ | 882589 |
| 19 | សូមស្លាប់ក្បែរទ្រូងប្រុស | 882590 |
| 20 | ពីមនុស្សម្នាក់ដែលអូនស្ងប់ចិត្ត | 882591 |
| 21 | ឈឺ | 882592 |
| 22 | កំលោះលួងចិត្ត | 882593 |
| 23 | លលាម | 882594 |
| 24 | ខ្លួនថៃផ្ទុកទឹកភ្នែក | 882595 |
| 25 | ព្រែះក្លួងបេះដូង | 882596 |
| 26 | ស្នេហ៍មានតំណាប | 882597 |
| 27 | ចង់ផ្លាស់ភពថ្មី | 882598 |
| 28 | ពីរនាក់ ផ្លូវពីរ | 882599 |
| 29 | បណ្ដាំស្នេហ៍ | 882600 |
| 30 | ខ្មាស់ខ្លួនបង | 882601 |




### Picture Messages




### Screen Logos




### Talent Search

ចង់ក្លាយជាតារាផ្សាយពាណិជ្ជកម្មរបស់ Cellcard ដែរឬទេ?
ចង់ក្លាយជាអ្នកឈ្នះរង្វាន់ Cellcard $50 ដែរឬទេ?
លោកអ្នកអាចក្លាយបានភ្លាមៗ ! ដោយគ្រាន់តែផ្ញើរូបថតថ្មីៗរបស់លោកអ្នក ដែលថតតាមបែបសម័យទំនើប ពេញមួយជំហរខ្លួនមួយសន្លឹកផ្ញើមកកាន់ប្រអប់សំបុត្រលេខ 808 ជាការស្រេច ។ ឱកាសល្អស្ថិតនៅក្នុងកណ្ដាប់ដៃលោកអ្នកហើយ កុំបណ្ដោយឲ្យឱកាសល្អនេះកន្លងផុតទៅឲ្យសោះ ! រូបថតដែលស្រស់ស្អាត ហើយលេចធ្លោជាងគេនឹងឈ្នះបាន Cellcard $50 ហើយក្លាយជាតារាពាណិជ្ជកម្ម Cellcard ទៀតផង ។

*សូមសរសេរពីប្រវត្តិរូបសង្ខេប និងលេខទូរស័ព្ទរបស់លោកអ្នកនៅខាងខ្នងរូបថត



# CONNECT




ពិភពលោកប្រារព្ធពិធីឆ្លងឆ្នាំ

បុណ្យឆ្លងឆ្នាំថ្មីនៅ៖ ស៊ីដនី ហុងកុង ភ្នំពេញ ម៉ាឌ្រីដ ក្រុងឡុងដ៍ ប្រេស៊ីល អាក្វាដ័រ ញ៉ូវយក

Cellcard ប្រារព្ធពិធីបុណ្យឆ្លងឆ្នាំដ៏ធំបំផុតនៅក្នុងទីក្រុងភ្នំពេញ

រឹតតែច្បាស់
cellcard

# ពិភពលោកប្រារព្ធពិធីបុណ្យចូលឆ្នាំថ្មី !

## អបអរសាទរពិធីបុណ្យចូលឆ្នាំថ្មី ឆ្នាំសកល !

សួស្តីឆ្នាំថ្មី ! សួស្តីឆ្នាំថ្មី !បើតុនកាលិបបន្តិច គេនិយាយថា Merry Christmas ឬ Happy New Year ! នេះគឺជាពាក្យដែលមនុស្សគ្រប់គ្នា និយាយជូនពរគ្នា ឬផ្ញើសារជូនពរគ្នាទៅវិញទៅមកចាប់ពីថ្ងៃទី 25 ដល់ថ្ងៃទី 31 ខែធ្នូ នៅរៀងរាល់ដំណាច់ឆ្នាំ ។

ពិធីបុណ្យអបអរសាទរ បុណ្យចូលឆ្នាំសកល ថ្វីត្បិតតែមិនសូវជាមានភាពគគ្រឹកគគ្រេងនៅស្រុកខ្មែរយើងក៏ពិតមែនតែសំរាប់បណ្តាប្រទេសផ្សេងមួយចំនួននៅលើពិភពលោកគឺមានភាពអធិកអធម និងសប្បាយរីករាយក្រៃលែង ។ អញ្ចឹងតោះ...! ធ្វើដំណើរទេសចរណ៍ទាំងអស់គ្នាទៅកាន់ប្រទេសដែលទទួលស្វាគមន៍ឆ្នាំថ្មីដំបូងគេ ហើយចាំហួសទៅប្រទេសបន្ទាប់ទៀត ដើម្បីដឹងពីរបៀបរៀបចំនៅតាមប្រទេសនិមួយៗ ថាតើគេប្រារព្ធពិធីចូលឆ្នាំខុសប្លែកគ្នាយ៉ាងណា ?

អ្នកចូលរួមអបអរពិធីចូលឆ្នាំថ្មី មកពីគ្រប់ទិសទីគ្រប់ជាតិសាសន៍ជាង 1.2 លាននាក់ បានមកជួបគ្នានៅត្រង់ចំណុចប្រសព្វមួយនៃទីក្រុងស៊ីដនី គឺនៅស្ពាន Harbour និងមហោស្រព Opera House ដែលជានិមិត្តរូបនៃទីក្រុងស៊ីដនី ។ ជួបជុំគ្នាសប្បាយក្អាកក្អាយនៅទីនោះ ដើម្បីរង់ចាំពេលវេលាថ្មីមកដល់ ។ ម៉ោង 12 កណ្តាលអធ្រាត្របានឈានមកដល់ កាំជ្រួចប្រហែលជា 80 000 កាំជ្រួចបានបាញ់ឡើងលើភ្លឺចិញ្ចាច ចំរុះពណ៌ លាន់សូរក្ទងក្ទាំងពាសពេញមេឃបានប្រែក្លាយទីក្រុងស៊ីដនីឲ្យទៅជាពិភពមួយដ៏ស្រស់ត្រកាល មើលទៅមិនចង់ឲ្យទិដ្ឋភាពក្នុងរាត្រីនោះរំលងផុតឡើយ ។







ប្រជាជន ហុង កុង រាល់ឆ្នាំតែងតែមកជួបជុំគ្នានៅចំកណ្តាលទីក្រុង ជាពិសេសនៅតាមឆ្នេរសមុទ្រ Causeway Bay និងនៅមុខផែ Tsim Sha Tsui ដើម្បីមើលភ្លើងគោមបញ្ជោះឡើងលើ នៅតាមចន្លោះអាគារខ្ពស់ៗតាមបណ្តោយកំពង់ផែ មើលទិដ្ឋភាពស្អាតៗប្លែកៗ ដែលតុបតែងជាភ្លើងអំពូលថ្លៃថ្លាក្បាច់ផ្សេងៗ នៅតាមវប្បធម៌បុរាណចិន មើលមិនចង់ដាក់ភ្នែក សប្បាយមិនចង់ឲ្យកន្លងផុតឡើយ ។ ម៉ោង 12 ជិតមកដល់ មនុស្សម្នាទាំងអស់បានមកជួបជុំគ្នាត្រៀមខ្លួនចាប់ផ្តើមរាប់ម៉ោងថយក្រោយ ដើម្បីអបអរសាទរការបើកទំព័រថ្មី ឆ្នាំថ្មី។




នៅក្នុងឱកាសបុណ្យចូលឆ្នាំសកលនេះ Cellcard នឹងរៀបចំនូវពិធីជប់លៀងមួយដ៏ធំបំផុតនៅក្នុងទីក្រុងភ្នំពេញ ដើម្បីអបអរសាទរការបើកទំព័រឆ្នាំថ្មី ឆ្នាំ 2007 ។ សូមអានអត្ថបទពត៌មានខាងក្រោម ដើម្បីចូលរួមពិធីជប់លៀងអបអរសាទរឆ្នាំថ្មីជាមួយ Cellcard ។




ជួបជុំគ្នាញ៉ាំអាហារពេលល្ងាចតាមបែបគ្រួសារ ជជែកកំសាន្តសប្បាយជាមួយគ្នារហូតដល់ពាក់កណ្តាលអធ្រាត្រ គឺជាទំនៀមទំលាប់ពីបុរាណនៃការប្រារព្ធពិធីបុណ្យចូលឆ្នាំថ្មីនៅប្រទេសអេស្ប៉ាញ ទីក្រុងម៉ាឌ្រីដ ដែលត្រូវបានប្រជាជនរក្សាតាំងពីបុរាណកាលរហូតមកដល់ពេលបច្ចុប្បន្ន ។ ការរង់ចាំរហូតដល់ពាក់កណ្តាលអធ្រាត្រនេះ គឺរង់ចាំស្តាប់សំលេង កណ្តឹងនាឡិកាពោធិ៍ ។ មនុស្សនៅក្នុងគ្រួសារម្នាក់ៗត្រូវញ៉ាំផ្លែទំពាំងបាយជូរឲ្យបាន 12 ផ្លែ ។ នាឡិកាវាយម្តងញ៉ាំមួយផ្លែ ញ៉ាំរហូតទាល់តែអស់ 12 ផ្លែ ទើបទទួលបាននូវភាពសុខសប្បាយនៅឆ្នាំថ្មី បន្ទាប់ពីនោះមកទើបម្នាក់ៗអាចនាំគ្នាចេញទៅកំសាន្តនៅខាងក្រៅបាន ។ នេះគឺជាទំនៀមទំលាប់មួយ ដែលមានលក្ខណៈខុសប្លែកពីគេ ។

នៅក្នុងទីក្រុងឡុងដ៍ប្រទេសអង់គ្លេស ប្រជាជននៅទីនោះប្រារព្ធពិធីបុណ្យចូលឆ្នាំថ្មី ដោយបានជួបជុំគ្នា រៀបចំពិធីជប់លៀងនៅទល់មុខនាឡិកា Big Ben ដ៏ធំ ដើម្បីរង់ចាំទ្រនិចនាឡិការំកិលដល់ម៉ោង 12 ពាក់កណ្តាលយប់ ។ នៅពេលសល់ 10 វិនាទី ឆ្លងចូលវិនាទីឆ្នាំថ្មី ម្នាក់ៗស្រែករាប់លេខថយក្រោយខ្លាំងៗ ពី 10 មកដល់ 1 ។ នៅពេលដល់លេខ 0 ស្នូរសំរែកស្រែកថា សួស្តីឆ្នាំថ្មី បានលាន់ឮរំពងអឺងកង ឯស្នូរកាំជ្រួចក៏ផ្ទុះព្រមជាមួយគ្នានោះដែរ ។







មនុស្សជាង 2 លាន នាក់បានមកផ្តុំគ្នានៅលើឆ្នេរសមុទ្រ Copacobana រៀបចំពិធីជប់លៀងដ៏ធំមួយនៅទីនោះ ដើម្បីឆ្លងឆ្នាំចាស់ចូលឆ្នាំថ្មី ។ ញ៉ាំអាហារ រាំលេងកំសាន្តព្រមទាំងច្រៀងតាមបទភ្លេងបែបប្រេស៊ីល ភាពសប្បាយរីករាយកើតមានតាំងពីល្ងាចរហូតដល់ភ្លឺនៅថ្ងៃទី 31 ខែធ្នូ ឈានចូលថ្ងៃទី 1 ខែមករា ។

នៅអេក្វាឌ័រប្រជាជននៅទីនោះគេប្រារព្ធពិធីបុណ្យចូលឆ្នាំរបស់ខ្លួនដោយរៀបចំធ្វើជារូបចំលាក់ផ្សេងៗ ពីឈើ ក្រដាសកាសែត ឬកំទេចក្រដាសផ្សេងៗទៀតដែលអាចធ្វើទៅបាន ធ្វើហើយយកមកដុតនៅចំកណ្តាលហ្វូងមនុស្សដែលកំពុងអង្គុយជុំគ្នាព័ទ្ធជុំវិញភ្លើង ។ នៅពេលដែលភ្លើងឆេះរូបចំលាក់នោះមនុស្សម្នាក់ៗត្រូវបួងសួងសូមអោយជួបតែសេចក្តីសុខសប្បាយ ចាប់ពីឆ្នាំថ្មីនេះតទៅ ។







ការរៀបចំពិធីបុណ្យចូលឆ្នាំថ្មីឆ្នាំសកលនៅសហរដ្ឋអាមេរិក មានទំហំធំជាងគេដែលត្រូវបានគេរៀបចំនៅបរិវេណទីធ្លាមួយដែលមានឈ្មោះថាប៉េម Times Square ។ បរិវេណនេះមានការរចនា និងតុបតែងភ្លឺចិញ្ចែងចិញ្ចាំងនៅកណ្តាលអធ្រាត្រមើលទៅប្រៀបដូចជាឋានមហាសោធ ។

ដើម្បីចូលរួមអបអរសាទរក្នុងពិធីបុណ្យចូលឆ្នាំថ្មីឆ្នាំសកលនេះ Cellcard នឹងរៀបចំពិធីជប់លៀងដ៏ធំមួយដែលមានឈ្មោះថា "រីករាយជប់លៀងជាមួយ Cellcard" នៅក្នុងទីក្រុងភ្នំពេញទល់មុខស្ថានីយ៍រថភ្លើង ដោយមានការរៀបចំឆាកសំដែងផ្ទាល់ មានការប្រគំតន្ត្រីដែលនឹងត្រូវបានអញ្ជើញចូលរួមដោយក្រុមតារាចម្រៀង Rock, Hip Hop តារាចម្រៀង Pop ល្បីៗ និងក្រុមរាំដែលមានទេពកោសល្យជាច្រើនរូបទៀតមកចូលរួមសំដែងក្នុងរាត្រីថ្ងៃទី 31 ខែធ្នូ ឆ្នាំ 2006 ។ នៅក្នុងពិធីជប់លៀងនោះ Cellcard នឹងរៀបចំកម្មវិធីផ្តល់រង្វាន់ដ៏ច្រើនសន្ធឹកសន្ធាប់ជូនដល់អតិថិជនរបស់ខ្លួនផងដែរ ។

សួស្តីឆ្នាំថ្មី ! សូមកុំភ្លេចចូលរួមស្វាគមន៍ក្នុងពិធីជប់លៀងបើកទំព័រឆ្នាំថ្មី ឆ្នាំ 2007 នៅទល់មុខស្ថានីយ៍រថភ្លើង វេលា ម៉ោង 8 យប់ ។

## Clearly it's time to party!

ប្រារព្ធពិធី
ឆ្លងឆ្នាំថ្មីជាមួយ
Cellcard !

§